ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្ដីការគណៈរដ្ឋមន្ត្រី
លេខៈ ១៣៥ សជណ

ថ្ងៃ អង្គារ ៩ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មករា ឆ្នាំ២០២៦

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**
**សូមជម្រាបជូន**

- **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
- **ឯកឧត្តមបណ្ឌិត ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាប្រធានគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ**
- **លោកជំទាវបណ្ឌិតសភាចារ្យ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងជាប្រធានក្រុមប្រឹក្សាភិបាលអាជ្ញាធរជាតិសំបូរព្រៃគុក**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងទេសចរណ៍**
- **ឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ**

**កម្មវត្ថុ ៖** ករណីគោរពស្នើសុំអនុញ្ញាតជាគោលការណ៍ដ៏ខ្ពង់ខ្ពស់ រៀបចំយន្តការអភិវឌ្ឍន៍ទេសចរណ៍ប្រាសាទសំបូរព្រៃគុក និងតំបន់ជុំវិញ និងអនុវត្តគម្រោងអាទិភាព។

**យោង ៖**
- លិខិតចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៦ របស់ក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តកំពង់ធំ
- ចំណារដ៏ខ្ពង់ខ្ពស់បំផុតរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០២៦។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ទីស្ដីការគណៈរដ្ឋមន្ត្រីសូមជម្រាបជូនឯកឧត្តមលោកជំទាវមេត្តាជ្រាបថា រាជរដ្ឋាភិបាលយល់ព្រមជាគោលការណ៍ដូចខាងក្រោម៖

១- ចំពោះយន្តការគ្រប់គ្រង និងអភិវឌ្ឍទេសចរណ៍ប្រាសាទសំបូរព្រៃគុក និងតំបន់ជុំវិញ ជូនគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ (គ.អ.ទ.ស) (**ឯកឧត្តម ថោង ខុន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស ជាប្រធាន និង**ឯកឧត្តម ហួត ហាក់** រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ជាអនុប្រធានអចិន្ត្រៃយ៍) និងមាន៖

- អាជ្ញាធរជាតិសំបូរព្រៃគុក ជាអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក (Sub-DMO) ដឹកនាំសម្របសម្រួល និងតាមដានការអភិវឌ្ឍទេសចរណ៍ក្នុងតំបន់បេតិកភណ្ឌប្រាសាទ

សំបូរព្រៃគុក (ក្នុងដែនកំណត់ដោយព្រះរាជក្រឹត្យលេខ នស/រកត/០២២០/២០៥ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីការបង្កើតអាជ្ញាធរជាតិដើម្បីការពារ និងអភិវឌ្ឍរមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុកជាគ្រឹះស្ថានសាធារណៈរដ្ឋបាល)

- គណៈកម្មាធិការអភិវឌ្ឍន៍ទេសចរណ៍ខេត្តកំពង់ធំ (រដ្ឋបាលខេត្តកំពង់ធំ ដែលមានអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំជាប្រធាន) ជាអង្គភាពគ្រប់គ្រងគោលដៅទេសចរណ៍ដោយឡែក (Sub-DMO) ដឹកនាំសម្របសម្រួលការអភិវឌ្ឍទេសចរណ៍តំបន់ក្រៅតំបន់បេតិកភណ្ឌប្រាសាទសំបូរព្រៃគុក (ស្ថិតក្នុងដែនរដ្ឋបាលខេត្តកំពង់ធំ)។

២- ជូនរដ្ឋបាលខេត្តកំពង់ធំនិងគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ សហការជាមួយអាជ្ញាធរជាតិសំបូរព្រៃគុក និងក្រសួងទេសចរណ៍ អនុវត្ត**គម្រោងទី១៖ «លើកកម្ពស់ភាពទាក់ទាញទេសចរណ៍តំបន់ប្រាសាទសំបូរព្រៃគុក និងតំបន់ជុំវិញ»**។

៣- ជូនគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ សហការជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងទេសចរណ៍ និងអាជ្ញាធរជាតិសំបូរព្រៃគុកអនុវត្ត**គម្រោងទី២៖ «កែលម្អបទពិសោធន៍ទេសចរណ៍ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថលក្នុងតំបន់ប្រាសាទសំបូរព្រៃគុក»**។

៤- ជូនរដ្ឋបាលខេត្តកំពង់ធំសហការជាមួយក្រុមប្រឹក្សាភិបាលសិក្សាទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍កម្ពុជា (CTB) អនុវត្ត**គម្រោងទី៣៖** យុទ្ធនាការផ្សព្វផ្សាយឌីជីថល **«សំបូរព្រៃគុក៖ បេតិកភណ្ឌមុនសម័យអង្គរ»** ។

៥- ជូនក្រសួងទេសចរណ៍អនុវត្ត**គម្រោងទី៤៖** កិច្ចការពង្រឹងគុណភាពសេវាកម្មទេសចរណ៍ក្រោមយុទ្ធនាការ **«ទីក្រុងស្អាត ភូមិស្អាត រមណីយដ្ឋានស្អាត សេវាកម្មល្អ បដិសណ្ឋារកិច្ចល្អ»**។

៦- ជូនគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍន៍ទេសចរណ៍សៀមរាប-អង្គរ ដឹកនាំកិច្ចប្រជុំអន្តរក្រសួងលើការរៀបចំ **«វិធានការគន្លឹះអភិវឌ្ឍន៍ទេសចរណ៍ប្រាសាទសំបូរព្រៃគុក និងតំបន់ជុំវិញឆ្នាំ២០២៦-២០៣០»**។

សេចក្តីដូចបានជម្រាបជូនខាងលើ សូមឯកឧត្តម លោកជំទាវមេត្តាជ្រាប និងចាត់ចែងអនុវត្ត។

**ឋ.រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**រដ្ឋលេខាធិការ**

**ឃឿន ណារត**

**ចម្លងជូន៖**
- ក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ
- អាជ្ញាធរជាតិសំបូរព្រៃគុក
- ឯកសារ កាលប្បវត្តិ